

Guidance Note

# សេចក្តីណែនាំពីយន្តការដោះស្រាយបណ្តឹងសារទុក្ខ

# គម្រោង Rise Up!

# សេចក្តីផ្តើម និងគោលបំណង

គម្រោងនេះគឺជាគំនិតផ្តួចផ្តើមមួយដែលដឹកនាំដោយអង្គការ RECOFTC សហការណ៍ក្នុងភាពជាដៃគូជាមួយអង្គការយេនឌ័រ និងអភិវឌ្ឍន៍ដើម្បីកម្ពុជា (GADC)។គម្រោងនេះបានទទួលការគាំទ្រថវិកាពីសហភាពអន្តរជាតិសម្រាប់ការអភិរក្សធម្មជាតិ (IUCN) តាមរយៈមូលនិធិប្រកួតប្រជែងដើម្បីជានាបាននូវនិរន្តរភាពបរិស្ថាន ដែលមានភាពធន់ និងបរិយាបន្ន (RISE) ដែលនឹងចាប់ផ្តើមដំណើរការចាប់ពីខែមករា ឆ្នាំ២០២៣ ដល់ខែធ្នូ ឆ្នាំ២០២៤។

គម្រោងមានគោលបំណងកាត់បន្ថយអំពើហិង្សាលើយេនឌ័រ ដើម្បីលើកម្ពស់ការចូលរួម និងភាពជាអ្នកដឹកនាំរបស់ស្ត្រីនៅក្នុងសហគមន៍តំបន់ការពារធម្មជាតិ និងសហគមន៍ព្រៃឈើ។ គម្រោងអនុវត្តឡើងដើម្បីស្ត្រីអាចចូលរួម និងគ្រប់គ្រងធនធានក្នុងសហគមន៍តំបន់ការពារធម្មជាតិ និងសហគមន៍ព្រៃឈើ។ គម្រោងផ្តោតលើការយកចិត្តទុកដាក់លើការការពារ ការផ្លាស់ប្តូរឥរិយាបថ និងអាកប្បកិរិយា ព្រមទាំងការកសាងបណ្តាញ។

គម្រោងនេះនឹងដំណើរការនៅក្នុងទីតាំងចំនួនប្រាំបីដែលត្រូវបានជ្រើសរើសក្នុងខេត្តកំពង់ឆ្នាំង និងខេត្តពោធិ៍សាត់ និងមានកិច្ចសហការជាមួយក្រសួងបរិស្ថាន ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងកិច្ចការនារី ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

សេចក្តីណែនាំនេះនឹងដាក់បញ្ចូលនូវនីតិវិធីសម្រាប់ការដាក់ស្នើ និងគ្រប់គ្រងយន្តការដោះស្រាយបណ្តឹងសារទុករបស់គម្រោង។ យន្តការនេះនឹងដោះស្រាយបណ្តឹងតវ៉ារបស់អ្នកពាក់ព័ន្ធអំពីផលប៉ះពាល់អវិជ្ជមានដែលអាចកើតឡើងដោយសារការអនុវត្តគម្រោង។ បញ្ហាទាំងនោះក៏អាចទាក់ទងនឹងការមិនគោរពគោលការណ៍ និងស្តង់ដារគ្រប់គ្រងបរិស្ថាន និងសង្គម ( ESMS ) ឬការប្រព្រឹត្តខុសរបស់បុគ្គលិកគម្រោងដែលអនុវត្តសកម្មភាពរបស់គម្រោង។

យន្តការនេះមានគោលបំណង បង្កើតជាផ្នែកមួយសម្រាប់ទំនាក់ទំនងជាមួយបុគ្គល ដែលគិតថាខ្លួនទទួលរងផលប៉ះពាល់អវិជ្ជមានតាមរយៈការអនុវត្តគម្រោង និងដើម្បី ពង្រឹងតម្លាភាព និងគណនេយ្យភាពរបស់បុគ្គលិកដែលអនុវត្តគម្រោងនេះ។ យន្តការនេះជួយកំណត់ស្វែងរកហានិភ័យនិងបញ្ហាដែលកើតឡើងកំឡុងពេលអនុវត្ត ធ្វើការកែលម្អសកម្មភាពគម្រោងតាមរយៈការកែសម្រួលការគ្រប់គ្រង និងតាមដាន ត្រួតពិនិត្យការអនុវត្តសកម្មភាព រួមទាំងការបង្កើនភាពជាម្ចាស់គម្រោង និងនិរន្តរភាព ក្នុងចំណោមបុគ្គលិកគម្រោង សហគមន៍ និងអ្នកពាក់ព័ន្ធ។

# ដំណើរការប្រតិបត្តិការ និងនីតិវិធីនៃយន្តការបណ្ដឹងដែលមានលក្ខណៈអាចទទួលយកបាន

- អង្គការ សហគមន៍ និងអ្នកពាក់ព័ន្ធផ្សេងទៀតអាចដាក់ពាក្យបណ្ដឹង ប្រសិនបើពួកគេជឿថា ពួកគេអាចរងផលប៉ះពាល់អវិជ្ជមានដែលបង្កដោយអង្គភាពប្រតិបត្តិដែលមិនគោរពគោលការណ៍ ស្តង់ដារ និងនីតិវិធីរបស់គម្រោង។

- អ្នកតំណាង (បុគ្គល ឬអង្គការក្នុងស្រុក) អាចដាក់ពាក្យបណ្ដឹងក្នុងនាមសហគមន៍អ្នកពាក់ព័ន្ធគម្រោង ឬក្រុមដែលរងផលប៉ះពាល់។ នៅពេលដាក់បណ្ដឹងសារទុក្ខ អ្នកតំណាងគួរតែផ្តល់ឈ្មោះសហគមន៍ ឬអង្គការដែលពួកគេធ្វើជាតំណាង ព្រមទាំងព័ត៌មានសម្រាប់ធ្វើការទំនាក់ទំនង។ អត្តសញ្ញាណរបស់អ្នកប្ដឹងនឹងត្រូវបានរក្សាទុកជាការសម្ងាត់។ ម៉្យាងវិញទៀត បណ្ដឹងអនាមិកក៏អាចទទួលយកបានផងដែរ ក្នុងករណីមានការព្រួយបារម្ភអំពីការរក្សាការសម្ងាត់របស់អ្នកប្ដឹង។

- ទម្រង់បែបបទដែលបានស្នើសម្រាប់បណ្ដឹងមាននៅក្នុងឧបសម្ព័ន្ធ១។ សូមកត់ចំណាំថា វាមិនមែនជាកាតព្វកិច្ចក្នុងការប្រើទម្រង់ជាក់លាក់នេះទេ។ វាគ្រាន់តែជាឧទាហរណ៍ស្តីពីប្រភេទព័ត៌មានដែលចាំបាច់ត្រូវបំពេញ និងប្រមូលសម្រាប់ដំណើរការដោះស្រាយបញ្ហាបន្ថែម។

- ពាក្យបណ្ដឹងដែលបានប្ដឹងបន្ទាប់ពីកាលបរិច្ឆេទនៃការបិទគម្រោងជាផ្លូវការគឺថ្ងៃទី៣១ ខែធ្នូ ឆ្នាំ ២០២៤ ឬ ១៨ខែ បន្ទាប់ពីកាលបរិច្ឆេទបិទជាផ្លូវការ ប្រសិនបើផលប៉ះពាល់ដែលបណ្ដាលមកពីសកម្មភាពគម្រោងមិនទាន់មាន ឬមិនអាចសមហេតុផល ត្រូវបានគេដឹងមុនបន្ទាប់ពីកាលបរិច្ឆេទបិទគម្រោងជាផ្លូវការ។

- បណ្ដឹងនានាដែលទាក់ទងនឹងច្បាប់ គោលនយោបាយ និងបទប្បញ្ញត្តិរបស់ប្រទេស លើកលែងតែវាមានការពាក់ព័ន្ធដោយផ្ទាល់ទៅនឹងកាតព្វកិច្ចរបស់អង្គការ RECOFTC ឬ GADC ក្នុងការអនុលោមតាមគោលការណ៍ និងស្តង់ដារគ្រប់គ្រងបរិស្ថាន និងសង្គម (ESMS) របស់គម្រោង។

# បណ្តាញនានាសម្រាប់ដាក់ពាក្យបណ្តឹង

យន្តការបណ្តឹងសារទុក្ខនេះអាចប្រើប្រាស់បានសម្រាប់មនុស្សគ្រប់រូបរួមមាន៖ ស្ត្រី ជនជាតិដើមភាគតិច និងក្រុមជនងាយរងគ្រោះផ្សេងទៀតនៅក្នុងតំបន់គោលដៅរបស់គម្រោង។

មានប្រព័ន្ធឬវិធីសាស្ត្រ ជាច្រើនដែលអាចប្រើប្រាស់សម្រាប់ដាក់ពាក្យបណ្តឹងនៅក្រោមគម្រោងនេះរួមមាន៖ តាមរយៈទូរស័ព្ទ អ៊ីមែល ប្រព័ន្ធផ្សព្វផ្សាយសង្គមអនឡាញ (ក្រុមតេលេក្រាម គេហទំព័រហ្វេសបុកផេករបស់អង្គការ RECOFTC) និងដោយផ្ទាល់។

## គណៈកម្មការជាតិ

អាស័យដ្ឋាន៖ RECOFTC Cambodia ៤០ មហាវិថីព្រះនរោត្តម សង្កាត់ផ្សារកណ្តាលទី២ ខណ្ឌដូនពេញ រាជធានីភ្នំពេញ។

អ៊ីមែល៖ cambodia@recoftc.org

ទូរស័ព្ទ៖ +855 23 998 784

តាមរយៈ Facebook Messenger: RECOFTC Cambodia

## គណៈកម្មការសហគមន៍

* នឹងផ្តល់ជូនព័ត៌មានបន្ទាប់ពីគណៈកម្មការសហគមន៍ត្រូវបានបង្កើតឡើងនៅក្នុងខេត្តកំពង់ឆ្នាំង និងខេត្តពោធិ៍សាត់

ប្រសិនបើបណ្តឹងមានភាពរសើបខ្លាំង ឬបើអ្នកតវ៉ាចង់ស្វែងរកការសម្ងាត់ ដើមបណ្តឹងគួរតែដាក់ពាក្យបណ្តឹងដោយផ្ទាល់ទៅកាន់គណៈកម្មការជាតិតាមរយៈទំនាក់ទំនងដែលបានផ្តល់ជូន ឬទៅកាន់យន្តការដោះស្រាយ បណ្តឹងសារទុក្ខរបស់មូលនិធិ RISE នៅកម្រិតតំបន់និងកម្រិតសកលតាមរយៈអ៊ីមែល៖ RISEGRM@iucn.org

# គណៈកម្មការធិការគ្រប់គ្រង

ដើម្បីឆ្លើយតបនឹងពាក្យបណ្ដឹង និងបញ្ហាប្រកបដោយប្រសិទ្ធភាព គម្រោងនឹងបង្កើត គណៈកម្មការដែលយន្តការដោះស្រាយបណ្ដឹងសារទុក្ខនៅថ្នាក់ជាតិ និងថ្នាក់សហគមន៍។

បញ្ហានានានឹងដោះស្រាយនៅកម្រិតសហគមន៍។ ដើមបណ្ដឹងគួរតែដាក់ពាក្យបណ្ដឹង របស់ពួកគេដោយផ្ទាល់ទៅគណៈកម្មការសហគមន៍។ ម៉្យាងវិញទៀត ប្រសិនបើបញ្ហា មិនត្រូវបានដោះស្រាយ ឬអ្នកប្ដឹងតវ៉ាមិនពេញចិត្តនឹងដំណោះស្រាយរបស់គណៈកម្មការ សហគមន៍ គេអាចលើកយកកង្វល់ទាំងនោះឡើងទៅគណៈកម្មាធិការថ្នាក់ជាតិ។

គណៈកម្មការថ្នាក់ជាតិនៃយន្តការដោះស្រាយបណ្ដឹងសារទុក្ខមានសមាជិកចំនួន៥ នាក់៖ អ្នកគ្រប់គ្រងគម្រោង១នាក់មកពី RECOFTC អ្នកគ្រប់គ្រងគម្រោង១នាក់មកពី GADC និង ៣នាក់ (មានស្ត្រីយ៉ាងហោចណាស់ម្នាក់) មកពីនាយកដ្ឋានរបស់រដ្ឋាភិបាលដែល សម្របសម្រួលសកម្មភាពតាមទីតាំងរបស់គម្រោងពីថ្នាក់ជាតិ និងខេត្ត។ គណៈកម្មការជាតិនឹងជួបប្រជុំរៀងរាល់ត្រីមាស និងកិច្ចប្រជុំពិសេស អាស្រ័យលើភាព បន្ទាន់និងតាមតម្រូវការ។ ពួកគេនឹងពិនិត្យមើលលើបណ្ដឹងសារទុក្ខ និងធ្វើការពិភាក្សាអំពី ជម្រើសផ្សេងៗសម្រាប់ដោះស្រាយ ព្រមទាំងរកវិធីសាស្ត្រដោះស្រាយ និងអនុវត្តសកម្មភាព របស់គម្រោងតាមតម្រូវការ។



គណៈកម្មការសហគមន៍នៃយន្តការដោះស្រាយបណ្ដឹងសារទុក្ខ ឬក្រុមការងាររបស់គម្រោងនឹងត្រូវបានបង្កើតឡើងនៅក្នុងគណៈកម្មការគ្រប់គ្រងដែលមានស្រាប់នៅតាមទីតាំងគម្រោងនីមួយៗ មួយក្រុមក្នុងខេត្តកំពង់ឆ្នាំង និងមួយក្រុមក្នុងខេត្តពោធិ៍សាត់។ ក្រុមការងារនេះនឹងមានមនុស្សបីនាក់ យ៉ាងហោចណាស់ មានស្ត្រីម្នាក់ និង/ឬតំណាង ១នាក់មកពីក្រុមជនជាតិដើមភាគតិច។ អ្នកតំណាងទាំងនោះ គឺជាអ្នកដឹកនាំសហគមន៍ដែលទទួលបានការគោរព ចេះអាន និងសរសេរជាភាសាខ្មែរ និងភាសាក្នុងតំបន់ ហើយមានបទពិសោធន៍ក្នុងការងារស្ម័គ្រចិត្ត ឬសម្របសម្រួលគម្រោង និងសកម្មភាពរបស់អង្គការមិនមែនរដ្ឋាភិបាល។

គណៈកម្មការសហគមន៍មានទំនួលខុសត្រូវក្នុងការទទួល ការស៊ើបអង្កេត និងដោះស្រាយបណ្ដឹងសារទុក្ខ ដោយមានការគាំទ្រពីគណៈកម្មការជាតិ។ ពួកគាត់ក៏មានទំនួលខុសត្រូវក្នុងការសម្របសម្រួលការឆ្លើយតបចំពោះអ្នកប្ដឹងតវ៉ា និងអនុវត្តសកម្មភាពចាំបាច់នានា។ គណៈកម្មការនឹងជួបប្រជុំរៀងរាល់ត្រីមាស និងកិច្ចប្រជុំពិសេស អាស្រ័យលើភាពបន្ទាន់ និងតម្រូវការ។ ពួកគេនឹងពិនិត្យមើលលើបណ្ដឹងតវ៉ា និងពិភាក្សាអំពីជម្រើសសម្រាប់ដោះស្រាយបញ្ហាទាំងនោះ។



# នីតិវិធី និងប្រព័ន្ធព័ត៌មាន

ប្រព័ន្ធព័ត៌មាននឹងត្រូវបានបង្កើតឡើងដើម្បីប្រមូល និងរៀបចំពាក្យបណ្តឹងដែលត្រូវបានដាក់ជូនតាមរយៈបណ្តាញផ្សេងៗ។ រាល់ពាក្យបណ្តឹងទាំងអស់នឹងត្រូវបានកត់ត្រា និងសរសេរកូដនៅក្នុងប្រព័ន្ធព័ត៌មាននៅពេលដែលពួកគេបានទទួលហើយដំណើរការនឹងត្រូវបានកត់ត្រាទុករហូតដល់ពាក្យបណ្តឹងនីមួយៗត្រូវបានដោះស្រាយរួចរាល់។

បន្ទាប់ពីពាក្យបណ្តឹងត្រូវបានដាក់ជូន អ្នកប្តឹង នឹងទទួលបានការបញ្ជាក់ថាបណ្តឹងរបស់ពួកគេត្រូវបានទទួល ប្រសិនបើព័ត៌មានលម្អិតទំនាក់ទំនងត្រូវបានផ្តល់ជូន។ អ្នកដែលត្រូវបានចាត់តាំងនៅក្នុងគណៈកម្មការជាតិ ឬនៅក្នុងគណៈកម្មការសហគមន៍នឹងទទួលព័ត៌មានសម្រាប់អនុវត្តសកម្មភាព និងបន្តតាមដាន។ អ្នកដែលត្រូវបានចាត់តាំងនៅក្នុងគណៈកម្មការជាតិ ឬនៅក្នុងគណៈកម្មការសហគមន៍នឹងជម្រាបជូនទៅអ្នកតវ៉ាថាពាក្យបណ្តឹងនេះមានលក្ខណៈអាចទទួលយកបាន ក្នុងរយៈពេលប្រាំថ្ងៃនៃថ្ងៃធ្វើការ។ ដើម្បីសម្រេចបាននូវការសម្រេចចិត្តនេះ គណៈកម្មការនឹងកោះប្រជុំមួយនៅកម្រិតដែលពាក់ព័ន្ធ ហើយនឹងចូលរួមជាមួយសមាជិកក្រុមគម្រោងដើម្បីធ្វើការវាយតម្លៃលើពាក្យបណ្តឹង។



ប្រសិនបើពាក្យបណ្ដឹងមានលក្ខណៈគ្រប់គ្រាន់ គណៈកម្មការនឹងធ្វើការស៊ើបអង្កេតទៅលើបណ្ដឹង ធ្វើការពិភាក្សាអំពីដំណោះស្រាយ រៀបចំផែនការសកម្មភាព អនុវត្ត និងធ្វើរបាយការណ៍អំពីវឌ្ឍនភាព។ ការស៊ើបអង្កេតអាចមានជាការចុះសួរសុខទុក្ខ និងសម្ភាសន៍ជាមួយអ្នកពាក់ព័ន្ធ។ កំណត់ហេតុនឹងត្រូវបានកត់ត្រា និងបញ្ចូលទៅក្នុងទិន្នន័យមូលដ្ឋាននៃយន្តការដោះស្រាយបណ្ដឹងសារទុក្ខ។ សូមពិនិត្យទៅលើឯកសារយោងស្តីពីដំណើរការជាជំហានៗសម្រាប់ការគ្រប់គ្រងបណ្ដឹងតវ៉ានៅក្នុងឧបសម្ព័ន្ធ២។

ព័ត៌មាន និងអត្តសញ្ញាណរបស់អ្នកប្ដឹងនឹងត្រូវបានរក្សាទុកជាការសម្ងាត់។ ព័ត៌មានដែលត្រូវការនៅក្នុងទម្រង់ បណ្ដឹងមានដូចខាងក្រោម៖
(១) ឈ្មោះដើមបណ្ដឹង
(២) សហគមន៍ ឬអង្គការ
(៣) បញ្ហា៖ តើមានអ្វីកើតឡើង កន្លែងណា ពេលណា និងអ្នកណា
(៤) ការយល់ព្រមក្នុងការចេញផ្សាយព័ត៌មានរបស់ដើមបណ្ដឹង៖ បាទ ឬ ទេ
(៥) ព័ត៌មានទំនាក់ទំនង៖ ឈ្មោះ លេខទូរស័ព្ទ និងអាស័យដ្ឋានអ៊ីមែល

អ្នកប្ដឹងអាចពិចារណាអំពីប្រភេទនៃបញ្ហាដែលត្រូវដាក់ជូនដូចខាងក្រោម៖
(១) សកម្មភាពទាក់ទងនឹងការមិនគោរពគោលការណ៍ និងស្តង់ដារ ESMS និងការប្រព្រឹត្តខុសរបស់បុគ្គលិកគម្រោង
(២) ការប្រើប្រាស់ថវិកាគម្រោងមិនត្រឹមត្រូវ រួមទាំងការក្លែងបន្លំ និងអំពើពុករលួយ
(៣) ការបំពានគោលនយោបាយ គោលការណ៍ណែនាំ និងនីតិវិធី
(៤) ការកេងប្រវ័ញ្ចផ្លូវភេទ ការរំលោភបំពានអំណាច/អន្តរាគមន៍ និងអំពើហិង្សាផ្អែកលើយេនឌ័រ

ការតវ៉ាឬមតិរិះគន់ដែលមានលក្ខណៈធ្ងន់ធ្ងរ រួមទាំងការពាក់ព័ន្ធនឹងអំពើហិង្សាផ្អែកលើយេនឌ័រ ឬការកេងប្រវញ្ចផ្លូវភេទដែលត្រូវបានលើកឡើងតាមរយៈយន្តការដោះស្រាយបណ្ដឹងសារទុក្ខកម្រិតគម្រោងក៏នឹងត្រូវបានរាយការណ៍ជូនទៅអ្នកគ្រប់គ្រងមូលនិធិប្រកួតប្រជែងរបស់ IUCN RISE ក្នុងរយៈពេល២៤ ម៉ោង។ IUCN នឹងជូនដំណឹងដល់ក្រុមប្រឹក្សា RISE ដែលមានសមាសភាពមកពី IUCN និង USAID ។

ក្នុងការឆ្លើយតបទៅនឹងការតវ៉ា និងបញ្ហាទាក់ទងនឹងអំពើហឹង្សាលើយេនឌ័រ បុគ្គលដែលត្រូវបានចាត់តាំងរបស់យន្តការដោះស្រាយបណ្តឹងសារទុក្ខនៅកម្រិតគម្រោង គឺត្រូវប្រកាន់ខ្ជាប់នូវវិធីសាស្ត្រដែលផ្តោតលើអ្នករស់រានមានជីវិត។ ពួកគេស្នើសុំការយល់ព្រមជាមុន មុនពេលបញ្ជូនអ្នកតវ៉ា ឬអ្នករស់រានមានជីវិតទៅកាន់សេវាកម្ម ផ្សេងៗ ពួកគេគោរពសិទ្ធិរបស់អ្នករស់រានមានជីវិត រួមទាំងឯកជនភាព និងការសម្ងាត់របស់អ្នកទាំងនោះដោយមិនមានការរើសអើង និងធានាបាននូវសុវត្ថិភាព។ បញ្ជីស្តីពីសេវាកម្មបញ្ជូនសម្រាប់ដោះស្រាយអំពើហឹង្សាលើយេនឌ័រនឹងត្រូវបានផ្តល់ជូនដល់អ្នករស់រានមានជីវិត។ អ្នកទទួលបន្ទុកដែលត្រូវបានចាត់តាំងរបស់គណៈកម្មការជាតិ និងគណៈកម្មការសហគមន៍ និងអ្នកគ្រប់គ្រងគម្រោងនឹងរៀបចំធ្វើផែនការសុវត្ថិភាពសម្រាប់អ្នករស់រានមានជីវិតដោយមានការពិគ្រោះយោបល់ជាមួយអ្នកឯកទេសផ្នែកយេនឌ័រ។ បុគ្គលិកគម្រោងដែលចូលរួមធ្វើការពាក់ព័ន្ធនឹងព័ត៌មានស្តីពីអំពើហិង្សាលើយេនឌ័រ នឹងទទួលបានការបណ្តុះបណ្តាលឱ្យប្រកាន់ខ្ជាប់នូវវិធីសាស្ត្រផ្តោតលើអ្នករស់រានមានជីវិត និងការអនុវត្តផ្សេងទៀតដែលបានរៀបរាប់ខាងលើ។

## ការផ្សព្វផ្សាយយន្តការដោះស្រាយបណ្តឹងសារទុក្ខ

ក្រុមការងារគម្រោងនឹងទទួលការបណ្តុះបណ្តាលស្តីពីយន្តការដោះស្រាយបណ្តឹងសារទុក្ខដែលជាផ្នែកមួយនៃការតម្រង់ទិសរបស់គម្រោង។

សេចក្តីណែនាំនេះនឹងត្រូវបានដាក់នៅលើគេហទំព័ររបស់អង្គការ RECOFTC និង GADC ។ ក្រុមការងារគម្រោងនឹងផ្តល់នូវព័ត៌មានស្តីពីទិដ្ឋភាពទូទៅនៃយន្តការនេះដល់ភាគីពាក់ព័ន្ធទាំងអស់នៅក្នុងព្រឹត្តិការណ៍នៃពិធីសម្ពោធជាផ្លូវការនៃការចាប់ផ្តើមគម្រោង និងនៅពេលធ្វើសកម្មភាពសំខាន់ៗ រួមទាំងការបណ្តុះបណ្តាល និងយុទ្ធនាការនៅតាមសហគមន៍។ ការផ្សព្វផ្សាយនេះក៏នឹងបើកឱកាសសម្រាប់អ្នកពាក់ព័ន្ធទាំងអស់ដើម្បីពិនិត្យ និងផ្តល់អនុសាសន៍ដើម្បីកែលម្អយន្តការរួម និងសេចក្តីណែនាំផងដែរ។

សេចក្តីណែនាំនេះនឹងធ្វើឡើងជាភាសាខ្មែរ ហើយព័ត៌មាននឹងត្រូវបានផ្សព្វផ្សាយដល់ភាគីពាក់ព័ន្ធនៅទីតាំងគម្រោងនៅពេលអនុវត្តសកម្មភាពគម្រោង។

# ឧបសម្ព័ន្ធ១៖
# ទម្រង់បែបបទដែលបានដាក់ស្នើសម្រាប់បណ្តឹង

១. ឈ្មោះដើមបណ្តឹង

..........................................................................................................................

២. ឈ្មោះសហគមន៍/អង្គការ

..........................................................................................................................

៣. បញ្ជូនទៅកាន់៖

☐ គណៈកម្មការសហគមន៍ (សូមកំណត់ឈ្មោះសហគមន៍)

..........................................................................................................................

☐ គណៈកម្មការជាតិ

☐ IUCN

4. ប្រភេទបញ្ហា

☐ សកម្មភាពទាក់ទងនឹងការមិនគោរពគោលការណ៍ ESMS និងស្តង់ដារ និងការប្រព្រឹត្តមិនត្រឹមត្រូវរបស់ បុគ្គលិកគម្រោង

☐ ការប្រើប្រាស់ថវិកាគម្រោងខុស រួមទាំងការក្លែងបន្លំ និងអំពើពុករលួយ

☐ ការបំពានគោលការណ៍ណែនាំ និងនីតិវិធី

☐ ការកេងប្រវ័ញ្ចផ្លូវភេទ និងការរំលោភបំពានអំណាច/អន្តរាគមន៍

☐ ផ្សេងៗ (សូមពណ៌នា) ..........................................................................................

..........................................................................................................................

៥. បរិបទបញ្ហា (សូមពណ៌នាអំពីអ្វីដែលបានកើតឡើង កន្លែងណា ពេលណា និងអ្នកណា)

..........................................................................................................

..........................................................................................................

..........................................................................................................

៦. សំណូមពរ ឬអនុសាសន៍សម្រាប់ដំណោះស្រាយ (ប្រសិនបើរ

..........................................................................................................

..........................................................................................................

..........................................................................................................

៧. ការយល់ព្រមឱ្យចេញផ្សាយព័ត៌មានរបស់ដើមបណ្ដឹង៖

☐ ទេ

៨. បញ្ជីឯកសារ និងឯកសារភ្ជាប់ (ប្រសិនបើមាន)

..........................................................................................................

..........................................................................................................

៩. ព័ត៌មានទំនាក់ទំនង

ឈ្មោះអ្នកទំនាក់ទំនង..........................................................................

លេខទូរស័ព្ទ......................................................................................

អាស័យដ្ឋានអ៊ីមែល...............................................................................

១០. កាលបរិច្ឆេទនៃការដាក់ពាក្យ...........................................................

# ឧបសម្ព័ន្ធ២:
# ដំណើរការជាជំហានៗសម្រាប់ការគ្រប់គ្រងបណ្តឹងសារទុក្ខ

| ជំហាន | គណៈកម្មការជាតិ | គណៈកម្មការសហគមន៍ |
|---|---|---|
| ១. ការទទួល និង ការរៀបចំពាក្យបណ្តឹង | អ្នកទទួលបន្ទុកនឹងរៀបចំពាក្យបណ្តឹងដែលបានទទួលដោយប្រើទម្រង់បែបបទទទួលផ្ទៃក្នុងនៅក្នុងឧបសម្ព័ន្ធ៣ នៅក្នុង ឯកសារអនឡាញដែលបានរៀបចំឡើង។ គេនឹងធ្វើការដាក់លេខកូដ និងតម្រៀបតាមប្រភេទរៀងៗខ្លួន។ | អ្នកទទួលបន្ទុករៀបចំពាក្យបណ្តឹងដែលទទួលបានដោយប្រើទម្រង់បែបបទទទួលផ្ទៃក្នុងនៅក្នុងឧបសម្ព័ន្ធ៣ នៅក្នុងឯកសារអនឡាញដែលបានរៀបចំឡើង។ |
| | អ្នកទទួលបន្ទុកធ្វើបច្ចុប្បន្នភាពជូនគណៈកម្មការលើការទទួលពាក្យបណ្តឹងតាមអ៊ីមែលជាមួយនឹងតំណភ្ជាប់ទៅកាន់ឯកសារដែលបានរៀបចំ។ | អ្នកទទួលបន្ទុកធ្វើបច្ចុប្បន្នភាពជូនគណៈកម្មការលើការទទួលពាក្យបណ្តឹងតាមរយៈការកោះហៅប្រជុំ។ |

| ជំហាន | គណៈកម្មការជាតិ | គណៈកម្មការសហគមន៍ |
|---|---|---|
| ២. បណ្តឹងដែលមានលក្ខណៈអាចទទួលយកបាន | គណៈកម្មការពិនិត្យពាក្យបណ្តឹង ពិភាក្សា និងសម្រេចអំពីបណ្តឹងដែលមានលក្ខណៈអាចទទួលយកបានក្នុងរយៈពេលប្រាំថ្ងៃនៃថ្ងៃធ្វើការ។<br><br>អ្នកទទួលបន្ទុកជូនដំណឹងដល់ដើមបណ្តឹង (ប្រសិនបើព័ត៌មានលម្អិតទំនាក់ទំនងត្រូវបានផ្តល់ជូន) ថាពាក្យបណ្តឹងមានលក្ខណៈអាចទទួលយកបានហើយបញ្ជាក់ថាគណៈកម្មការនឹងអនុវត្តការស៊ើបអង្កេត ហើយនិងធ្វើការរាយការណ៍អំពីវឌ្ឍនភាព និងសកម្មភាពដែលពួកគេបានអនុវត្ត។<br><br>ឬ<br><br>អ្នកទទួលបន្ទុកជូនដំណឹងដល់ដើមបណ្តឹង (ប្រសិនបើព័ត៌មានលម្អិតទំនាក់ទំនងត្រូវបានផ្តល់ជូន) ថាពាក្យបណ្តឹងមិនមាន លក្ខណៈអាចទទួលយកបាន ព្រមទាំងធ្វើការពន្យល់លម្អិត។ | គណៈកម្មការពិនិត្យពាក្យបណ្តឹង ពិភាក្សា និងសម្រេចអំពីបណ្តឹងដែលមានលក្ខណៈអាចទទួលយកបានក្នុងរយៈពេលប្រាំថ្ងៃនៃថ្ងៃធ្វើការ។<br><br>គណៈកម្មការក៏ជូនដំណឹងដល់អ្នកទទួលបន្ទុកថ្នាក់ជាតិដើម្បីធ្វើបច្ចុប្បន្នភាព និងស្វែងរកការគាំទ្រណាមួយដែលត្រូវការដើម្បីស៊ើបអង្កេតនិងដោះស្រាយបណ្តឹង។<br><br>អ្នកទទួលបន្ទុកជូនដំណឹងដល់ដើមបណ្តឹង (ប្រសិនបើព័ត៌មានលម្អិតទំនាក់ទំនងត្រូវបានផ្តល់ជូន)ថាពាក្យបណ្តឹងមានលក្ខណៈ អាចទទួលយកបាន។ហើយបញ្ជាក់ថាគណៈកម្មការនឹងអនុវត្តការស៊ើបអង្កេតហើយនិងធ្វើការរាយការណ៍អំពីវឌ្ឍនភាព និងសកម្មភាពដែលពួកគេបានអនុវត្ត។<br><br>ឬ<br><br>អ្នកទទួលបន្ទុកជូនដំណឹងដល់ដើមបណ្តឹង (ប្រសិនបើព័ត៌មាន ទំនាក់ទំនងលម្អិតត្រូវបានផ្តល់ជូន) ថាពាក្យបណ្តឹងមិនមាន លក្ខណៈអាចទទួលយកបាន ព្រមទាំងធ្វើការពន្យល់លម្អិត។ |

| ជំហាន | គណៈកម្មការជាតិ | គណៈកម្មការសហគមន៍ |
|---|---|---|
| ៣.ការស៊ើបអង្កេត | គណៈកម្មការពិភាក្សា និងបង្កើតផែនការអនុវត្តការស៊ើបអង្កេតដើម្បីទទួលបានរូបភាពច្បាស់លាស់អំពីស្ថានភាពជុំវិញបណ្តឹងសារទុក្ខក្នុងរយៈពេល១០ ថ្ងៃនៃថ្ងៃធ្វើការ។<br><br>សកម្មភាពទាំងនោះរួមមានការចុះសួរសុខទុក្ខ និងសម្ភាសន៍ជាមួយអ្នកពាក់ព័ន្ធ។ កំណត់ហេតុនឹងត្រូវបានកត់ត្រា និងបញ្ចូលទៅក្នុងយន្តការទិន្នន័យមូលដ្ឋាន។ | គណៈកម្មការពិភាក្សា និងបង្កើតផែនការអនុវត្តការស៊ើបអង្កេតដើម្បីទទួលបានរូបភាពច្បាស់លាស់អំពីស្ថានភាពជុំវិញបណ្តឹងសារទុក្ខក្នុងរយៈពេល១០ ថ្ងៃនៃថ្ងៃធ្វើការ។<br><br>សកម្មភាពទាំងនោះរួមមានការចុះសួរសុខទុក្ខ និងសម្ភាសន៍ជាមួយអ្នកពាក់ព័ន្ធ។ កំណត់ហេតុនឹងត្រូវបានកត់ត្រា និងបញ្ចូលទៅក្នុងយន្តការទិន្នន័យមូលដ្ឋាន។ |

| ដំណាក់កាល | គណៈកម្មការជាតិ | គណៈកម្មការសហគមន៍ |
|---|---|---|
| សកម្មភាព | នៅពេលបញ្ចប់ការស៊ើបអង្កេត គណៈកម្មាធិការធ្វើការកំណត់សកម្មភាពចាំបាច់ក្នុងការដោះស្រាយពាក្យបណ្ដឹង និងពេលវេលាក្នុងការអនុវត្តសកម្មភាពទាំងនោះ។<br><br>នៅក្នុងដំណើរការនេះ គណៈកម្មការអាចធ្វើការទំនាក់ទំនងជាមួយដើមបណ្ដឹង ឬតំណាងអ្នកប្ដឹងនៅក្នុងសហគមន៍ក្នុងការរៀបចំដំណោះស្រាយ និងផែនការសកម្មភាពតាមឆន្ទៈ និងសំណើរបស់ពួកគេ (ដូចដែលបានស្នើសុំក្នុងទម្រង់បែបបទបណ្ដឹងសារទុក្ខ)។ | នៅពេលបញ្ចប់ការស៊ើបអង្កេត គណៈកម្មាធិការធ្វើការកំណត់សកម្មភាពចាំបាច់ក្នុងការដោះស្រាយពាក្យបណ្ដឹង និងពេលវេលាក្នុងការអនុវត្តសកម្មភាពទាំងនោះ។<br><br>នៅក្នុងដំណើរការនេះ គណៈកម្មការអាចធ្វើការទំនាក់ទំនងជាមួយដើមបណ្ដឹង ឬតំណាងអ្នកប្ដឹងនៅក្នុងសហគមន៍ក្នុងការរៀបចំដំណោះស្រាយ និងផែនការសកម្មភាពតាមឆន្ទៈ និងសំណើរបស់ពួកគេ (ដូចដែលបានស្នើសុំក្នុងទម្រង់បែបបទបណ្ដឹងសារទុក្ខ)។ |
| ការតាមដាន និងវាយតម្លៃ | នៅដំណាច់ឆ្នាំទី១នៃការអនុវត្តគម្រោង គណៈកម្មការពិនិត្យករណីដែលបានចុះបញ្ជី ហើយឆ្លុះបញ្ចាំងពីដំណើរការ និងធ្វើការកែលម្អយន្តការ និងសេចក្ដីណែនាំតាមការចាំបាច់។ | នៅដំណាច់ឆ្នាំទី១នៃការអនុវត្តគម្រោង គណៈកម្មការពិនិត្យករណីដែលបានចុះបញ្ជី ហើយឆ្លុះបញ្ចាំងពីដំណើរការ និងធ្វើការកែលម្អយន្តការ និងសេចក្ដីណែនាំតាមការចាំបាច់។ |

# ឧបសម្ព័ន្ធ៣:
# ទម្រង់បែបបទនៃការទទួលពាក្យផ្ទៃក្នុង

| កូដ | ឈ្មោះអ្នកប្តឹង | ប្រភេទបញ្ហា | ទីកន្លែងដែលបញ្ហាកើតឡើង | អាទិភាព | កម្រិតរបស់គណៈកម្មការ | សំណូមពរ ឬ អនុសាសន៍សម្រាប់ដោះស្រាយបញ្ហាប្រសិនបើមាន | ការយល់ព្រមឱ្យចេញផ្សាយព័ត៌មានរបស់ដើមបណ្តឹង | ព័ត៌មានទំនាក់ទំនង | វឌ្ឍនភាព | សំគាល់ |
|---|---|---|---|---|---|---|---|---|---|---|
| ០០១ | ដើមបណ្តឹង ១ | សំណួរស្តីពីសិទ្ធិប្រើប្រាស់មូលនិធិគម្រោង | XXXXX | មធ្យម | សហគមន៍ | រៀបចំផ្ទាំងរូបភាពជាភាសាក្នុងស្រុកដើម្បីផ្សព្វផ្សាយអំពីចំណាយផ្សេងៗដែលពួកគេអាចធ្វើការចំណាយបានក្រោមគម្រោងក្នុងសហគមន៍ និងផ្តល់ការបណ្តុះបណ្តាលឡើងវិញដល់បុគ្គលិក។ | | | | |
| | | | | | | | | | | |

# RECOFTC

RECOFTC ជឿជាក់ថាទៅអនាគតប្រជាជនក្នុងតំបន់អាស៊ី-ប៉ាស៊ីហ្វិកនឹងរស់នៅដោយសមតុល្យភាព និងចីរភាពជាមួយនឹងការជួយដល់សុខភាពព្រៃឈើ និងភាពសុំាក្នុងតំបន់ទេសភាព។

យើងប្រើប្រាស់អភិក្រមរយៈពេលវែងប្រកបដោយបរិយាប័ន្នក្នុងការគាំទ្រប្រជាសហគមន៍មូលដ្ឋានក្នុងការការពារដី និងសិទ្ធិរបស់គេ បញ្ឈប់ការកាប់បំផ្លាញព្រៃឈើ ស្វែងរកជម្រើសនៃមុខរបរ និងលើកកម្ពស់សមភាពយេនឌ័រ។ យើងគឺជាអង្គការក្រៅរដ្ឋាភិបាលដែលមិនយករកចំណេញតែមួយគត់ក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក។ យើងមានបទពិសោធន៍លើស៣៥ឆ្នាំ និងធ្វើការជាមួយមនុស្សនិងព្រៃឈើ និងកសាងទំនុកចិត្តជាមួយអ្នកពាក់ព័ន្ធគ្រប់ជាន់ថ្នាក់។ យើងពង្រឹកភាពជាដៃគូជាមួយអ្នកពាក់ព័ន្ធជាមួយស្ថាប័នពហុភាគីដល់រដ្ឋាភិបាល វិស័យឯកជន និងប្រជាសហគមន៍មូលដ្ឋាន។ ចំណេះដឹងនិងគំនិតផ្តួចផ្តើមរបស់យើងអាចឱ្យប្រទេសនានាលើកកម្ពស់ការគ្រប់គ្រងព្រៃឈើប្រសើរឡើង កាត់បន្ថយ និងសម្របខ្លួនទៅនឹងការប្រែប្រួលអាកាសធាតុ និងសម្រេចបានគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពរបៀបវារៈរបស់អង្គការសហប្រជាជាតិឆ្នាំ២០៣០។




រីខូហ្វកម្ពុជា
រដ្ឋបាលព្រៃឈើ
អាគារលេខ៤០ មហាវិថីព្រះនរោត្តម
សង្កាត់ផ្សារកណ្តាល២
ខណ្ឌដូនពេញ
ភ្នំពេញ, កម្ពុជា
លេខទូរស័ព្ទទំនាក់ទំនង៖+៨៥៥ (០)២៣ ៩៩៨ ៧៨៤

@RECOFTC

recoftc.org



ម្ចាស់ជំនួយ

Schweizerische Eidgenossenschaft
Confédération suisse
Confederazione Svizzera
Confederaziun svizra

Swiss Agency for Development
and Cooperation SDC

Sweden
Sverige

ការងាររបស់ RECOFTC អាចធ្វើទៅបានដោយមានការគាំទ្រពីទីភ្នាក់ងារសម្រាប់ការអភិវឌ្ឍ
និងកិច្ចសហប្រតិបត្តិការស្វីស (SDC) និងទីភ្នាក់ងារស៊ុយអែតសម្រាប់កិច្ចសហប្រតិបត្តិការអភិវឌ្ឍអន្តរជាតិ